# ការវិភាគរួមផ្នែកច្បាប់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីអំពីសហជីពនៃសហគ្រាស

ថ្ងៃនេះ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ចេញនូវការវិភាគផ្នែកច្បាប់មួយនៃសេចក្តីព្រាងច្បាប់ស្តីអំពីសហជីពនៃសហគ្រាស (ច្បាប់ស្តីអំពីសហជីពពាណិជ្ជកម្ម) ចុងក្រោយ ដែលបានទទួលកាលពីចុងខែឧសភា ឆ្នាំនេះ។ នៅពេលដែលសហជីពបានចាប់ផ្តើមធ្វើយុទ្ធនាការ ស្តីអំពីការទាមទារតំឡើងប្រាក់ឈ្នួលអប្បបរមា ១៧៧ដុល្លា អាមេរិក ក្នុងមួយខែនៅទូទាំងប្រទេសកាលពីម្សិលមិញ សេចក្តីព្រាងច្បាប់ស្តីអំពីសហជីពពាណិជ្ជកម្ម បង្ហាញអំពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការជ្រៀតជ្រែក និងរំលោភបំពានលើសកម្មភាព និងការបង្កើតសហជីព។

មុនព្រឹត្តិការណ៍កាលពីម្សិលមិញរបស់សហជីពដែលបានគ្រោងទុក យោធាដែលមកពីកងពលលេខ ៧០ និង ៩៩ រួមបញ្ចូលទាំងកងកាំភ្លើងធំ ត្រូវបានដាក់ត្រៀមនៅតាមដងផ្លូវវេង ស្រេង និងនៅខាងក្នុងសួនឧស្សាហកម្មកាណាឌីយ៉ា នេះបានបង្ហាញពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការគំរាមកំហែង និងរំខានមេដឹកនាំសហជីព ក៏ដូចជាសិទ្ធិសេរីភាពរបស់កម្មករក្នុងការបញ្ចេញមតិ ក្នុងការជួបជុំ និងការចូលរួមផងដែរ។

មុនព្រឹត្តិការណ៍កាលពីម្សិលមិញ ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញបានរៀបចំដីកាចោទជាមួយនឹងចៅក្រមស៊ើបអង្កេតដោយចោទប្រកាន់តំណាងសហជីពចំនួន ៦នាក់រួមមាន៖ លោក ប៉ាវ ស៊ីណា ប្រធានសហព័ន្ធសហជីពចលនាកម្មករ (CUMW) លោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTU) លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU) លោក ម៉ម ញឹម ប្រធានសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយភ័ណ្ឌកាត់ដេរកម្ពុជា (NIFTUC) អ្នកស្រី យ៉ាង សោភ័ណ្ឌ ប្រធានសម្ព័ន្ធសហជីពកម្ពុជា (CATU) និងលោក រ៉ុង ឈុន ប្រធានសមាគមន៍គ្រូបង្រៀនឯករាជ្យ (CITA) ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស (មាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ) គំរាមកំហែងនឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ (មាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ) និងប្រើមធ្យោបាយដើម្បីជាឧបសគ្គដល់ចរាចរណ៍សាធារណៈ (មាត្រា ៧៨ នៃច្បាប់ចរាចរណ៍ផ្លូវគោក) ពាក់ព័ន្ធនឹងបាតុកម្មរបស់កម្មករដែលបានកើតឡើងនៅជុំវិញទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤។

ទោះបីជាចៅក្រមស៊ើបសួរបានចេញដីការកោះទៅកាន់តំណាងសហជីពទាំង ៦នាក់រួចហើយក៏ដោយ ក៏ប៉ុន្តែកន្លងមកគឺមានតែលោក ប៉ាវ ស៊ីណា និងលោក ជា មុនី តែប៉ុណ្ណោះដែលត្រូវបានធ្វើការសាកសួរ។ បន្ទាប់ពីត្រូវបានសាកសួរពីសំណាក់ចៅក្រមស៊ើបអង្កេត អ្នកទាំងពីរត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ ចំពោះលោក ប៉ាវ ស៊ីណា ចៅក្រមមិនទាន់បានដាក់លក្ខខណ្ឌចំពោះការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការនោះទេ ប៉ុន្តែលោក ជា មុន្នី ត្រូវបានដាក់លក្ខខណ្ឌដោយហាមឃាត់មិនឲ្យមានការជួបជុំជាមួយនឹងតំណាងសហជីពដ៏ទៃទៀតឡើយ។

អ្នកនាង ណាលី ពីឡូក នាយិការបស់អង្គការ លីកាដូ បានមានប្រសាសន៍ថា៖ "ការប្រើប្រាស់កងកម្លាំងយោធាដើម្បីបំភិតបំភ័យ និងគំរាមកំហែងកម្មករពីការចូលរួមសកម្មភាពរបស់សហជីព គឺមិនអាចទទួលយកបានឡើយ ដែលសកម្មភាពទាំងអស់នេះត្រូវបានបន្តរំលោភបំពានលើប្រព័ន្ធយុត្តិធម៌ នឹងមានគោលបំណងបម្រើឲ្យផលប្រយោជន៍នយោបាយ"។ "ភាពខុសគ្នានៅក្នុងវិធានការណ៍ទៅលើរវាងមេដឹកនាំសហជីព និងកងសន្តិសុខរបស់រាជរដ្ឋាភិបាល មិនដែលមានភាពច្បាស់លាស់ទាល់តែសោះ ដោយមិនទាន់មានការចោទប្រកាន់នៅតុលាការណាមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការសម្លាប់មនុស្សចំនួន ៥នាក់ ដោយកងសន្តិសុខមួយចំនួនអំឡុងពេលដូចគ្នានោះ។"

ការអ្វីដែលនៅតែស្ថិតនៅពីក្រោយកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីតែគម្រាមកំហែងកម្មករ និងមេដឹកនាំសហជីព នៅខណៈដែលយុទ្ធនាការតំឡើងប្រាក់ឈ្នួលថ្មីបានចាប់ផ្តើម គឺសេចក្តីព្រាងច្បាប់ស្តីពីសហជីពនៃសហគ្រាស ដែលជាការគម្រាមកំហែងយ៉ាងធំដល់សេរីភាពនៃការជួបជុំ នៅក្នុងទម្រង់បច្ចុប្បន្នរបស់ច្បាប់នេះ។ ការវិភាគដែលត្រូវបានធ្វើដោយមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) រកឃើញថា សេចក្តីព្រាងចុងក្រោយដែលត្រូវបានចេញផ្សាយនៅចុងខែឧសភាឆ្នាំនេះ បន្តគម្រាមកំហែងសិទ្ធិរបស់កម្មករក្នុងការជួបជុំដោយសេរី តាមរយៈលក្ខខណ្ឌតម្រូវឲ្យចុះបញ្ជី ក៏ដូចជាការរឹតបណ្តឹងដែលមិនច្បាស់លាស់ និងសម្រេចតែលើមន្ត្រីរាជការ លើសកម្មភាព និងស្វ័យភាពរបស់សហជីព។ ការវិភាគបានរកឃើញថាសេចក្តីព្រាងច្បាប់ ក៏អះអាងក្នុងការពង្រីកការគ្រប់គ្រងរបស់ក្រសួងការងារដោយមិនត្រឹមត្រូវដោយផ្ទេរអំណាចយ៉ាងច្រើនដល់ក្រសួង ដែលអំណាចទាំងនេះគួរតែស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ។

លោក មឿន តុលា ប្រធានកម្មវិធីសិទ្ធិការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់អប់រំសហគមន៍ (CLEC) បានមានប្រសាសន៍ថា៖ "នីតិរដ្ឋដ៏រឹងមាំដែលអាចកសាងទំនុកចិត្ត និងភាពជឿជាក់ពីសាធារណៈជន ទៅលើរាជរដ្ឋាភិបាលអាចធ្វើឡើងទៅបានដោយការអនុម័ត និងការពង្រឹងច្បាប់ដែលការពារសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ។ លោកបានបន្តទៀតថា៖ "សេចក្តីព្រាងច្បាប់ដែលមានការគំរាមកំហែង រំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ត្រូវតែធ្វើការកែប្រែដោយមានតម្លាភាព និងមានការចូលរួម ហើយប្រសិនបើមិនមានការកែប្រែនោះទេ អស្ថិរភាពសង្គម និងសេដ្ឋកិច្ចនឹងមានការកើតឡើង។"

យើងអំពាវនាវស្នើសុំឲ្យមានការត្រួតពិនិត្យសារឡើងវិញ នូវសេចក្តីព្រាងច្បាប់ចុងក្រោយបំផុតស្តីពីសហជីពនៃសហគ្រាស ដើម្បីធានាឲ្យមានការការពារពេញលេញនូវសិទ្ធិជាមូលដ្ឋានរបស់កម្មករ ក្នុងការចូលរួមជួបជុំដោយសេរីដើម្បីថែរក្សា និងធ្វើឲ្យប្រសើឡើងនូវលក្ខខណ្ឌការងាររបស់អ្នកទាំងនោះ ក៏ដូចជាអនុញ្ញាតឲ្យសហជីពអនុវត្តសិទ្ធិរបស់អ្នកទាំងនោះក្នុងការតថ្លៃជាសមូហភាព។

*សម្រាប់ព័តមានលម្អិត សូមទំនាក់ទំនង៖*

លោក មឿន តុលា ប្រធានកម្មវិធីសិទ្ធិការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់អប់រំសហគមន៍ (CLEC)
អ៊ីមែល: tola@clec.org.kh
គេហទំព័រ: http://www.clec.org.kh/